**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៥ សហវ

ថ្ងៃព្រហស្បតិ៍ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២

# សេចក្តីណែនាំ
# ស្តីពី
# ការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែឧសភា ឆ្នាំ២០២២ សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីឱ្យការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែឧសភា ឆ្នាំ២០២២ បានទាន់ពេលវេលា ស្របតាមសេចក្តីជូនដំណឹងលេខ ១៨០៧/២២ មសស.សជណ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែឧសភា ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម÷

**១.រដ្ឋបាលថ្នាក់ជាតិ**

-ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវត្រៀមរៀបចំបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស និងប្រាក់កម្រៃប្រចាំខែឧសភា ឆ្នាំ២០២២ និងដោយឡែកក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅថ្នាក់កណ្តាលដែលអនុវត្តតាមនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានរបបកំណត់ច្បាស់លាស់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបង្កើតប្រតិបត្តិការចំណាយបៀវត្ស និងប្រាក់កម្រៃប្រចាំខែឧសភា ឆ្នាំ២០២២ នៅក្នុងប្រព័ន្ធ FMIS និងស្កែនឯកសារពាក់ព័ន្ធឱ្យបានត្រឹមត្រូវ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ (រតនាគារថ្នាក់កណ្តាល ឬ រតនាគាររាជធានី ខេត្ត) យ៉ាងយូរត្រឹមសប្តាហ៍ទី៣ នៃខែមេសា ឆ្នាំ២០២២ ដើម្បីធានាដល់ការបើកផ្តល់បៀវត្ស និងប្រាក់កម្រៃលើកទី១សម្រាប់ខែឧសភា ឆ្នាំ២០២២ ឱ្យបានមុនដំណាច់ខែមេសា និងលើកទី២ ឱ្យបានក្នុងសប្តាហ៍ទី៣ នៃខែឧសភា ឆ្នាំ២០២២។

-ដោយឡែកក្រសួងការពារជាតិ ត្រូវបើកផ្តល់បៀវត្សប្រចាំខែឧសភា នៅក្នុងសប្តាហ៍ទី៣ នៃខែឧសភា ឆ្នាំ២០២២។

**២.រដ្ឋបាលថ្នាក់ក្រោមជាតិ**

-រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលខណ្ឌ ត្រូវត្រៀមរៀបចំបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែឧសភា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបញ្ជូនទៅដល់រតនាគាររាជធានី ខេត្ត យ៉ាងយូរត្រឹមសប្តាហ៍ទី៣ នៃខែមេសា ដើម្បីធានាដល់ការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភលើកទី១សម្រាប់ខែឧសភា ឆ្នាំ២០២២ ឱ្យបានមុនដំណាច់ខែមេសា និងលើកទី២ ឱ្យបានក្នុងសប្តាហ៍ទី៣ នៃខែឧសភា ឆ្នាំ២០២២។

-រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ត្រូវត្រៀមរៀបចំបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែឧសភា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត យ៉ាងយូរត្រឹម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

សប្តាហ៍ទី៣ នៃខែមេសា ឆ្នាំ២០២២ ដើម្បីធានាដល់ការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភលើកទី១សម្រាប់ខែឧសភា ឆ្នាំ២០២២ ឱ្យបានមុនដំណាច់ខែមេសា និងលើកទី២ ឱ្យបានក្នុងសប្តាហ៍ទី៣ នៃខែឧសភា ឆ្នាំ២០២២។

ការបើកផ្តល់បៀវត្សសម្រាប់ខែមិថុនា ឆ្នាំ២០២២ ត្រូវអនុវត្តតាមនីតិវិធីដែលបានកំណត់ជាធរមាន។

ក្រោយពីទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។/.

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋានថវិកា
- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ